ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការរៀបចំពិធីប្រកាសតែងតាំង និងស្រោចស្រពព្រះសុគន្ធវារី សម្ដេចព្រះសង្ឃនាយករងចំនួន ០៣អង្គ នៃគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.**_

ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីប្រកាសតែងតាំង និងស្រោចស្រពព្រះសុគន្ធវារីសម្ដេចព្រះសង្ឃនាយករងចំនួន ០៣អង្គ នៃគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្ដមទេសរដ្ឋមន្ត្រី | **ហ៊ឹម ឆែម** | ប្រធាន |
| ២. សម្ដេចព្រះពុទ្ធជ័យមុនី | **ឃឹម សន** | អនុប្រធាន |
| ៣. ឯកឧត្ដម | **យូ ស៊ីនឡុង** | អនុប្រធាន |
| ៤. ឯកឧត្ដម | **ខឡី វិស្សុត** | អនុប្រធាន |
| ៥. ឯកឧត្ដម | **ហ៊ុន ស៊ីថា** | សមាជិក |
| ៦. ឯកឧត្ដម | **ឈិន កេតនា** | សមាជិក |
| ៧. ឯកឧត្ដម | **ឆ្លោក ផន** | សមាជិក |
| ៨. ឯកឧត្ដម | **បួន លីមហេង** | សមាជិក |

| | | |
|---|---|---|
| ៩. ឯកឧត្តម | **ឃួន ស្រេង** | សមាជិក |
| ១០.ព្រះពុទ្ធវង្ស | **ហ៊ី ឈីវនាថ** | សមាជិក |

**ប្រការ២._**

គណៈកម្មការនេះ មានភារកិច្ចដូចតទៅ ៖

-សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជាដើម្បីរៀបចំពិធីបុណ្យស្រោចស្រពព្រះសុគន្ធវារី តាមប្រពៃណីព្រះពុទ្ធសាសនា ឲ្យប្រព្រឹត្តទៅបានល្អប្រសើរ

-ពិនិត្យ និងលើកសំណើដោះស្រាយបញ្ហានានា ទាក់ទិននឹងការរៀបចំពិធីបុណ្យខាងលើ

-រៀបចំកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងពិធីបុណ្យឲ្យបានល្អប្រសើរ

-ធ្វើលិខិតអញ្ជើញ រៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំ និងភ្ញៀវដែលអញ្ជើញចូលរួម

-លើកគម្រោង និងចាត់ចែងគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋ និងសប្បុរសជន ក្នុងការបម្រើឲ្យពិធីបុណ្យប្រព្រឹត្តទៅបានដោយរលូន និងល្អប្រសើរ

-បំពេញភារកិច្ចជាក់ស្តែងផ្សេងទៀត តាមការចាំបាច់សម្រាប់បម្រើឲ្យពិធីបុណ្យ។

**ប្រការ៣._**

គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការ និងក្រុមការងារបន្ថែមជាជំនួយការ និងប្រើប្រាស់មន្ត្រីក្រោមឱវាទតាមការចាំបាច់ ដើម្បីជានាឲ្យការរៀបចំពិធីបុណ្យប្រព្រឹត្តទៅតាមប្រពៃណីព្រះពុទ្ធសាសនាឲ្យបានល្អប្រសើរ។ គណៈកម្មការនេះ អាចប្រើប្រាស់ត្រាក្រសួងធម្មការ និងសាសនា ដើម្បីដំណើរការសកម្មភាពការងាររបស់ខ្លួន។

**ប្រការ៤._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៣ កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

*-គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា*
*-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
*-ក្រសួងការពារជាតិ*
*-ក្រសួងមហាផ្ទៃ*
*-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*-គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ*
*-សាលារាជធានីភ្នំពេញ*
*-រាជកិច្ច*
*-ដូចប្រការ៤ "ដើម្បីអនុវត្ត"*
*-ឯកសារ-កាលប្បវត្តិ*